Washington State Health Care Authority

# សំណួរសួរញឹកញាប់សម្រាប់អតិថិជនអំពីឯកជនភាពនៃទិន្នន័យ Apple Health

**អតិថិជន Apple Health (Medicaid)៖** សូមប្រើ frequently asked questions (សំណួរសួរញឹកញាប់, FAQ) ទាំងនេះ ដើម្បីស្វែងយល់បន្ថែមអំពីឯកជនភាពរបស់អ្នក និងរបៀបដែលគេចែករំលែកព័ត៌មានរបស់អ្នក។

ចំពោះព័ត៌មានបន្ថែម សូមអានសេចក្តីប្រកាស ឬមើល FAQ របស់ដៃគូ ឬសហគមន៍។

## តើមានអ្វីបានកើតឡើង?

Health Care Authority (អាជ្ញាធរសុខាភិបាល, HCA) ផ្ញើព័ត៌មានផ្ទាល់ខ្លួនដូចជា ឈ្មោះ អាសយដ្ឋាន លេខទូរសព្ទរបស់អ្នក និងសេវាកម្មថែទាំសុខភាពដែលអ្នកទទួលបានទៅកាន់ Centers for Medicare and Medicaid Services (មជ្ឈមណ្ឌលសម្រាប់សេវា Medicare និង Medicaid, CMS)។ CMS គឺជាទីភ្នាក់ងារសហព័ន្ធដែលដំណើរការកម្មវិធី Medicaid។

HCA ជឿជាក់ ប៉ុន្តែមិនអាចបញ្ជាក់ថា ព័ត៌មាននេះត្រូវបានចែករំលែកជាមួយ Department of Homeland Security (ក្រសួងសន្តិសុខមាតុភូមិ, DHS) នោះទេ។ HCA បានដឹងរឿងនេះពីព័ត៌មានដែលបានចេញផ្សាយនៅថ្ងៃទី 13 ខែមិថុនា ឆ្នាំ 2025។

## ហេតុអ្វីបានជារឿងនេះកើតឡើង?

រឿងនៅក្នុងព័ត៌មាននិយាយថា CMS ត្រូវបានប្រាប់ឱ្យផ្តល់ព័ត៌មាននេះដល់ DHS ដោយអ្នកដឹកនាំនៅ U.S. Department of Health and Human Services (ក្រសួងសុខាភិបាល និងសេវាមនុស្ស, HHS) សហរដ្ឋអាមេរិក។ HHS គ្រប់គ្រងកម្មវិធីថែទាំសុខភាពជាច្រើននៅទូទាំងប្រទេស ហើយ CMS គឺជាផ្នែកមួយនៃក្រសួង HHS។

## តើព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកណាត្រូវបានចែករំលែក?

HCA ផ្ញើព័ត៌មានទៅ CMS សម្រាប់អ្នកដែលបានចុះឈ្មោះក្នុងកម្មវិធី Apple Health ដែលទទួលបានមូលនិធិពីសហព័ន្ធ។ នេះរួមបញ្ចូលទាំងការពង្រីកកម្មវិធី Apple Health។

ឥឡូវនេះ យើងមិនដឹងច្បាស់ថាតើ CMS ចែករំលែកអ្វីជាមួយ DHS នោះទេ។ យើងមានការព្រួយបារម្ភថា DHS អាចមានព័ត៌មានផ្ទាល់ខ្លួនអំពីមនុស្សភាគច្រើនដែលប្រើកម្មវិធី Apple Health (Medicaid)។

## តើខ្ញុំអាចការពារព័ត៌មានរបស់ខ្ញុំដោយការលុបចោលកម្មវិធី Apple Health បានទេ?

ទេ ការលុបចោលការធានារ៉ាប់រងពី Apple Health របស់អ្នកឥឡូវនេះនឹងមិនយកមកវិញនូវព័ត៌មានដែលបានចែករំលែកជាមួយ CMS រួចហើយនោះទេ។

រដ្ឋទាំងអស់ត្រូវបានតម្រូវឱ្យចែករំលែកព័ត៌មាននេះជាមួយរដ្ឋាភិបាលសហព័ន្ធអស់រយៈពេលជាច្រើនឆ្នាំមកហើយ។

## ហេតុអ្វីបានជា HCA ចែករំលែកព័ត៌មានរបស់ខ្ញុំជាមួយ CMS?

រដ្ឋាភិបាលសហព័ន្ធផ្តល់ប្រាក់ដល់រដ្ឋដើម្បីជួយចំណាយលើកម្មវិធី Apple Health (Medicaid)។ ដើម្បីទទួលបានប្រាក់នេះ HCA ត្រូវបានតម្រូវដោយច្បាប់ឲ្យចែករំលែកព័ត៌មានជាមួយ CMS។

## ខ្ញុំមានការធានារ៉ាប់រងលើការពង្រីកកម្មវិធី Apple Health។ តើព័ត៌មានរបស់ខ្ញុំត្រូវបានគេចែករំលែកដែរទេ?

បាទ/ចាស។ ប្រសិនបើអ្នកបានចុះឈ្មោះក្នុងការពង្រីកកម្មវិធី Apple Health ព័ត៌មានរបស់អ្នកត្រូវបានចែករំលែកជាមួយ CMS។ ទោះបីជាសេវាភាគច្រើននៃការពង្រីកកម្មវិធី Apple Health ត្រូវបានបង់ដោយរដ្ឋក៏ដោយ ក៏ប្រាក់សហព័ន្ធត្រូវបានប្រើប្រាស់សម្រាប់ករណីទៅទទួលសេវាថែទាំសុខភាពបន្ទាន់ដែរ។

**តើឋានៈអន្តោប្រវេសន៍របស់ខ្ញុំត្រូវបានចែករំលែកជាមួយ CMS ដែរឬទេ?**

ព័ត៌មានអំពីឋានៈអន្តោប្រវេសន៍ដែលបញ្ជូនដោយ HCA ទៅ CMS មិនបញ្ជាក់ពីឋានៈអន្តោប្រវេសន៍លម្អិតរបស់បុគ្គលណាម្នាក់ទេ។ សម្រាប់អ្នកចុះឈ្មោះក្នុងការពង្រីកកម្មវិធី Apple Health ឋានៈអន្តោប្រវេសន៍សម្រាប់ស្ទើរតែគ្រប់គ្នាត្រូវបានរាយការណ៍ថា៖

- 'ពលរដ្ឋដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់' នេះសំដៅទៅលើបុគ្គលដែលមិនមែនជាពលរដ្ឋដែលទទួលបានឋានៈអន្តោប្រវេសន៍ជាក់លាក់ ឬ
- អ្នកទទួលសេវាកម្មសង្គ្រោះបន្ទាន់ មានន័យថា អ្នកមានសិទ្ធិទទួលបានសេវាកម្មសង្គ្រោះបន្ទាន់នៅក្រោមកម្មវិធី Medical សង្គ្រោះបន្ទាន់សម្រាប់ជនបរទេស ឬ
- ត្រូវបានរាយបញ្ជីថា 'ផ្សេងទៀត' មានន័យថា មិនមានប្រភេទផ្សេងទៀតដែលពណ៌នាអំពីឋានៈអន្តោប្រវេសន៍របស់អ្នកឡើយ។

**តើព័ត៌មាននេះនឹងត្រូវប្រើប្រាស់ដោយ DHS យ៉ាងដូចម្តេច?**

យើងមិនដឹងថាតើព័ត៌មានអំពីឋានៈអន្តោប្រវេសន៍នឹងត្រូវប្រើប្រាស់យ៉ាងដូចម្តេចនោះទេ។ យើងបារម្ភថាវាអាចត្រូវបានប្រើសម្រាប់ការអនុវត្តច្បាប់អន្តោប្រវេសន៍។

## តើខ្ញុំគួរធ្វើដូចម្តេចប្រសិនបើ DHS ប្រើព័ត៌មានរបស់ខ្ញុំសម្រាប់អនុវត្តច្បាប់អន្តោប្រវេសន៍?

ក្នុងករណីអ្នកព្រួយបារម្ភអំពីការអនុវត្តច្បាប់អន្តោប្រវេសន៍ សូមចូលទៅកាន់ផ្នែកដឹងពីសិទ្ធិរបស់អ្នក៖ការអនុវត្តច្បាប់អន្តោប្រវេសន៍ស៊ីវិល របស់ការិយាល័យអគ្គរដ្ឋអាជ្ញានៃរដ្ឋ Washington នៅក្នុងគេហទំព័ររបស់ នៅទីក្រុង Washington ដើម្បីស្វែងយល់អំពីសិទ្ធិរបស់អ្នកតាមអាសយដ្ឋាន ។

គេហទំព័រនេះមានព័ត៌មានដែលអាចជួយអ្នកឱ្យត្រៀមខ្លួន ប្រសិនបើអ្នកត្រូវបានទាក់ទងដោយមន្ត្រីអនុវត្តច្បាប់អន្តោប្រវេសន៍។ អ្នកអាចបកប្រែគេហទំព័រទៅជាភាសាជាច្រើនដោយប្រើឧបករណ៍នៅផ្នែកខាងឆ្វេងនៃអេក្រង់ ឬមើលឯកសារបកប្រែអំពីដឹងពីសិទ្ធិរបស់អ្នកនៅទំព័រទី 3។

## តើខ្ញុំអាចដកខ្លួនចេញពីការចែករំលែកព័ត៌មានរបស់ខ្ញុំជាមួយរដ្ឋាភិបាលសហព័ន្ធបានទេ?

ទេ ប្រសិនបើអ្នកមានការធានារ៉ាប់រងរបស់កម្មវិធី Apple Health អាជ្ញាធរ HCA តម្រូវឱ្យចែករំលែកព័ត៌មានរបស់អ្នកជាមួយរដ្ឋាភិបាលសហព័ន្ធ។ ចំណុចនេះតម្រូវដោយច្បាប់។ អ្នកមិនអាចជ្រើសរើសដកខ្លួនចេញទេ។

អ្នកអាចជ្រើសរើសលុបចោលការធានារ៉ាប់រងនៃកម្មវិធី Apple Health របស់អ្នកបានគ្រប់ពេល។ ស្វែងយល់ពីរបៀបលុបចោលការធានារ៉ាប់រងរបស់អ្នកតាមអនឡាញ។ ការលុបចោលការធានារ៉ាប់រងពី Apple Health របស់អ្នកឥឡូវនេះនឹងមិនយកមកវិញនូវព័ត៌មានដែលបានចែករំលែកជាមួយ CMS រួចហើយនោះទេ។

## តើខ្ញុំអាចដឹងដោយរបៀបណាថាព័ត៌មានរបស់ខ្ញុំត្រូវបានគេចែករំលែក?

ប្រសិនបើអ្នកបានចុះឈ្មោះក្នុងកម្មវិធី Apple Health ឬអ្នកបានចុះឈ្មោះពីមុន ព័ត៌មានរបស់អ្នកត្រូវបានចែករំលែកជាមួយ CMS តាមតម្រូវការ។

នេះរាប់បញ្ចូលទាំងអ្នកដែលបានចុះឈ្មោះ ឬនៅក្នុងបញ្ជីរង់ចាំសម្រាប់ការពង្រីកកម្មវិធី Apple Health ដែលបានទទួលសេវាថែទាំសុខភាពតាមរយៈកម្មវិធី Apple Health ផ្សេងទៀត។

ព័ត៌មានរបស់អ្នកមិនត្រូវបានចែករំលែកទេ ប្រសិនបើអ្នកបានដាក់ពាក្យសុំកម្មវិធី Apple Health ប៉ុន្តែត្រូវបានបដិសេធ និងមិនដែលបានចុះឈ្មោះ។

## តើអ្វីទៅជាជម្រើសរបស់ខ្ញុំសម្រាប់ការធានារ៉ាប់រងសុខភាព ប្រសិនបើខ្ញុំលុបចោលកម្មវិធី Apple Health?

ប្រសិនបើអ្នកទៅមន្ទីរពេទ្យ អ្នកអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានជំនួយក្នុងការចំណាយលើសេវាថែទាំតាមរយៈច្បាប់ស្តីពីសេវាថែទាំសុខភាពដោយសប្បុរសធម៌របស់រដ្ឋ Washington។ អ្នកក៏អាចទទួលបានសេវាថែទាំសុខភាពដោយឥតគិតថ្លៃ ឬក្នុងតម្លៃកាត់បន្ថយនៅគ្លីនិកឥតគិតថ្លៃ ឬមជ្ឈមណ្ឌលសុខភាពសហគមន៍ផងដែរ។

## តើខ្ញុំផ្លាស់ប្តូរអាសយដ្ឋាន ឬលេខទូរសព្ទរបស់ខ្ញុំដោយរបៀបណា?

ចូលទៅកាន់គេហទំព័រ hca.wa.gov/report-a-change ដើម្បីស្វែងយល់ពីរបៀបធ្វើបច្ចុប្បន្នភាពព័ត៌មានទំនាក់ទំនងរបស់អ្នក។ ការណែនាំមានជាភាសាជាច្រើន។

HCA ធ្វើបច្ចុប្បន្នភាពអាសយដ្ឋានផ្លាស់ប្តូរម្តងក្នុងមួយខែ។ ដោយសារយើងត្រូវបានតម្រូវឱ្យបញ្ជូនឯកសារប្រចាំខែទៅ CMS ព័ត៌មានអាសយដ្ឋានដែលបានធ្វើបច្ចុប្បន្នភាពនឹងត្រូវបានផ្ញើទៅ CMS បន្ទាប់ពីវាត្រូវបានធ្វើបច្ចុប្បន្នភាព។ CMS រក្សាព័ត៌មានពីមុនទាំងអស់។ នេះមានន័យថា ពួកគេនឹងបន្តមានសិទ្ធិចូលមើលព័ត៌មានលម្អិតនៃទំនាក់ទំនងទាំងចាស់ និងថ្មីរបស់អ្នក។

## តើរដ្ឋការពារព័ត៌មានរបស់ខ្ញុំដោយរបៀបណា?

HCA ត្រូវបានតម្រូវដោយច្បាប់រដ្ឋ និងសហព័ន្ធឲ្យប្រើប្រាស់ ឬចែករំលែកព័ត៌មានសុខភាពរបស់អ្នកសម្រាប់តែហេតុផលជាក់លាក់ប៉ុណ្ណោះ។

HCA កំពុងចាត់វិធានការដើម្បីកំណត់ចំនួនព័ត៌មានដែលត្រូវចែករំលែក។ ជាឧទាហរណ៍ យើងលែងចែករំលែកព័ត៌មានសេវាកម្មវេជ្ជសាស្ត្រភាគច្រើន (ហៅផងដែរថាការទាមទារសំណង) សម្រាប់អ្នកដែលបានចុះឈ្មោះក្នុងការពង្រីកកម្មវិធី Apple Health ទៀតហើយ។ យើងនៅតែត្រូវបានតម្រូវដែលឱ្យចែករំលែកព័ត៌មានការចុះឈ្មោះក្នុងការពង្រីកកម្មវិធី Apple Health ក៏ដូចជាទិន្នន័យសម្រាប់ការទាមទារសំណងសម្រាប់សេវាសង្គ្រោះបន្ទាន់ដែលបានទទួល ការព្យាបាលជំងឺមហារីក ឬការលាងឈាម ឬការថែទាំក្រោយប្តូរសរីរាង្គ។ សេវាកម្មទាំងនេះត្រូវបានគាំទ្រដោយមូលនិធិសហព័ន្ធ ដូច្នេះ HCA នៅតែត្រូវរាយការណ៍។

HCA កំពុងស្វែងរកមធ្យោបាយល្អប្រសើរជាងមុន ដើម្បីផ្តល់ឱ្យមនុស្សនូវការថែទាំដែលពួកគេត្រូវការខណៈពេលដែលការចែករំលែកទិន្នន័យកាន់តែតិចជាងមុន។ យើងកំពុងធ្វើការជាមួយការិយាល័យអភិបាលរដ្ឋ និងដៃគូផ្សេងទៀតដើម្បីធ្វើការផ្លាស់ប្តូរឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

## តើខ្ញុំនៅតែគួរទៅតាមការណាត់ជួបផ្នែកវេជ្ជសាស្ត្ររបស់ខ្ញុំ ឬទៅទទួលវេជ្ជបញ្ជារបស់ខ្ញុំដដែលឬ?

បាទ/ចាស។ វាជាការសំខាន់ដែលបន្តទទួលបានការថែទាំដែលអ្នកត្រូវការ។ យើងចង់ឱ្យអ្នកមានអារម្មណ៍ថាមានសុវត្ថិភាពក្នុងការទទួលបានសេវាថែទាំសុខភាពដែលអ្នកត្រូវការ។ យើងកំពុងធ្វើការជាមួយសហគមន៍អ្នកផ្តល់សេវា ដើម្បីជួយពួកគេឱ្យយល់ពីសិទ្ធិរបស់អ្នក និងបន្តផ្តល់ការថែទាំសុខភាពប្រកបដោយសុវត្ថិភាព និងមានលទ្ធភាពទទួលបានសម្រាប់មនុស្សគ្រប់គ្នានៅក្នុងរដ្ឋ Washington។

## តើខ្ញុំអាចទាក់ទងអ្នកណាបាន បើខ្ញុំមានសំណួរ និងកង្វល់អំពីឯកជនភាពរបស់ខ្ញុំ?

### អត្ថប្រយោជន៍សាធារណៈ និងអន្តោប្រវេសន៍

**ប្រសិនបើអ្នកព្រួយបារម្ភអំពីរបៀបដែលការប្រើប្រាស់អត្ថប្រយោជន៍សាធារណៈអាចប៉ះពាល់ដល់អ្នក** សូមពិគ្រោះជាមួយមេធាវីអន្តោប្រវេសន៍។ អ្នកអាចស្វែងរកជំនួយផ្នែកច្បាប់ដោយមិនគិតថ្លៃ ឬតម្លៃទាបនៅរដ្ឋ Washington តាមរយៈគេហទំព័រ immigrationlawhelp.org។ គេហទំព័រនេះជួយជនអន្តោប្រវេសន៍ដែលមានប្រាក់ចំណូលទាបស្វែងរកការគាំទ្រផ្នែកច្បាប់ដែលអាចទុកចិត្តបាន។

ចំពោះព័ត៌មានបន្ថែមអំពីរបៀបដែលអត្ថប្រយោជន៍សាធារណៈអាចប៉ះពាល់ដល់ឋានៈអន្តោប្រវេសន៍របស់អ្នក សូមចូលមើល ដំណើរការ និងនីតិវិធីនៃការគិតថ្លៃសេវាសាធារណៈរបស់ USCIS។

### ដឹងពីសិទ្ធិរបស់អ្នក

បើអ្នកព្រួយបារម្ភអំពី DHS មានព័ត៌មានរបស់អ្នក សូមចូលទៅកាន់ផ្នែកដឹងពីសិទ្ធិរបស់អ្នក៖ ការអនុវត្តច្បាប់អន្តោប្រវេសន៍ស៊ីវិលរបស់ការិយាល័យមេធាវីរដ្ឋ Washington នៅក្នុងគេហទំព័ររបស់រដ្ឋ Washington។ ចុចភាសាខាងក្រោមសម្រាប់ឯកសារដែលបានបកប្រែ។

Amharic | Arabic | Chinese (Simplified) | Chinese (traditional) | German | Hindi | Japanese | Khmer | Korean | Marshallese | Punjabi | Russian | Samoan | Somali | Spanish | Tagalog | Ukrainian | Vietnamese

## តើខ្ញុំអាចទទួលបានព័ត៌មានបន្ថែមនៅកន្លែងណា?

ដើម្បីអានបន្ថែមអំពីរបៀបដែល HCA ការពារព័ត៌មានរបស់អ្នក សូមចូលទៅកាន់គេហទំព័រ hca.wa.gov/apple-health-privacy។